**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១២៣៧ ព.ណ.នធ....

ថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០២០

## សេចក្តីជូនដំណឹង

នាយកដ្ឋាននាំចេញ-នាំចូល មានកិត្តិយសសូមជម្រាបជូន អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ និងអ្នកនាំចេញទំនិញទៅកាន់ទីផ្សារអាស៊ានទាំងអស់ឲ្យបានជ្រាបថា៖ ដើម្បីឲ្យស្របតាមការតម្រូវរបស់លេខាធិការដ្ឋានបញ្ជរតែមួយអាស៊ាន (ASEAN Single Window) ស្តីពីការដាក់ឲ្យអនុវត្តវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី តាមប្រព័ន្ធអេឡិចត្រូនិក (e-Form D) នាយកដ្ឋាននឹងធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ សម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (CO Form D) ចាប់ពី ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ នេះតទៅ លើចំនុចដូចខាងក្រោម៖

- ដកចេញព័ត៌មានមធ្យោបាយដឹកជញ្ជូន (ដូចជា៖ BY SEA, BY TRUCK, BY AIR) ក្នុងប្រអប់លេខ៣ (Means of Transport)
- ដាក់បង្ហាញ HS Code ដែលបានចុះបញ្ជីមុខទំនិញក្នុងប្រព័ន្ធនៅជួរទីមួយនៃ Description ទំនិញនីមួយៗក្នុងប្រអប់លេខ៧ ជាស្វ័យប្រវត្តិ
- ដាក់បង្ហាញបរិមាណវេចខ្ចប់ (amount of package) នៅជួរចុងក្រោយនៃ Description ទំនិញនីមួយៗក្នុងប្រអប់លេខ៧ ជាស្វ័យប្រវត្តិ .
- ដាក់បង្ហាញលេខរៀង Item Number នៃ Description ទំនិញនីមួយៗក្នុងប្រអប់លេខ៥ ជាស្វ័យប្រវត្តិ
- អនុញ្ញាតឲ្យអ្នកនាំចេញចុះបញ្ជីមុខទំនិញក្នុងប្រព័ន្ធជាមួយ HS Code របស់ប្រព័ន្ធបានដល់ 10 ខ្ទង់ ឬ 11 ខ្ទង់
- តម្រូវឲ្យអ្នកនាំចេញបញ្ចូលទឹកប្រាក់ (FOB Value) តាមមុខទំនិញនីមួយៗដូចក្នុងវិក័យបត្រទំនិញដែលបានភ្ជាប់
- តម្រូវឲ្យអ្នកនាំចេញពិនិត្យមើល CO Form D ដែលបាន Approved រួចនៅលើប្រព័ន្ធតាមរយៈតំណភ្ជាប់៖ https://docs.nsw.gov.kh/public-search/atiga ដើម្បីដឹងថា CO Form D នោះបានទទួលដោយប្រព័ន្ធរបស់ប្រទេសនាំចូល ជាទម្រង់អេឡិចត្រូនិក (ATIGA e-Form D is received by destination country)

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ជូន អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ និងអ្នកនាំចេញទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469